# ព្រឹត្តិប័ត្រ អំពី ការបើកសាលា

*ព្រឹត្តិប័ត្រជូនដំណឹងដល់ មាតាបិតា និងសិស្សានុសិស្ស ដែលប៉ះទង្គិច ដោយ ការបិទសាលា ការផ្លាស់ទីកន្លែង និងការបញ្ចូលគ្នា ដើម្បីត្រៀមខ្លួនសម្រាប់ថ្ងៃចូលរៀនដំបូង*



## ក្រសួងអប់រំ និងដៃគូរបស់សាលាក្រុង រួបរួមគ្នាដើម្បីធ្វើយ៉ាងណាឲ្យមានសុវត្ថិភាពតាមផ្លូវសម្រាប់សិស្សានុសិស្ស

តាមការរួបរួមគ្នាជាមួយទីក្រុងហ្វីឡាដែលហ្វ្យា៉ អង្គការ Town Watch Integrated Services (TWIS) ជាអង្គការដែលប្តេជ្ញាធ្វើឲ្យទីក្រុងហ្វីឡាដែលហ្វ្យា៉ ជាកន្លែងដែលមានសុវត្ថិភាពដល់ការរស់នៅ និងការប្រកបកិច្ចការ បានសហការគ្នាបង្កើតក្រុមមួយ ដែលប្តេជ្ញាបង្កើនសុវត្ថិភាពតាមផ្លូវសម្រាប់សិស្សានុសិស្ស ក្នុងកំឡុងឆ្នាំសិស្សាខាងមុខនេះ។

WalkSafePHL នឹងជួយ មាតាបិតា និងសិស្សានុសិស្ស ក្នុងសហគមន៍ដើម្បីសម្រេចថាតើផ្លូវណាមួយ ដែលសិស្សានុសិស្សគប្បីធ្វើដំណើរទៅ និងមក ពីសាលា ដោយផ្តល់ការហ្វឹកហ្វឺន និងផ្តល់សម្ភារៈផ្សេងៗ។ បន្ទាប់មក អ្នកស្ម័គ្រចិត្តដែលជាមនុស្សពេញវ័យនឹងតាមពិនិត្យមើលផ្លូវក្នុងកំឡុងឆ្នាំសិក្សា ហើយជួយធ្វើយ៉ាងណាឲ្យសិស្សានុសិស្សធ្វើដំណើរមកដល់ទីដៅរបស់ពួកគេដោយសុវត្ថិភាព។

ការិយាល័យទទួលបន្ទុកផ្នែកសន្តិសុខនៅសាលានៃក្រសួងអប់រំ បានសហការយ៉ាងជិតស្និទ្ធជាមួយ TWIS ដើម្បីជំរុញក្រុមគ្រួសារ និងសហគមន៍ ឲ្យចូលរួមជាមួយកម្មវិធី WalkSafePHL នៅរដូវក្តៅនេះ។ អគ្គស្នងការ Dorsey ទទួលបន្ទុកផ្នែកសន្តិសុខរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉ បានមានប្រសាសន៍ថា «ការិយាល័យរបស់យើងខ្ញុំ ប្តេជ្ញាផ្តល់បរិយាកាសដែលមានសុវត្ថិភាពដល់សិស្សានុសិស្ស» «ហើយការធ្វើឲ្យមានសុវត្ថិភាពតាមផ្លូវគឺជាជំហានដ៏សំខាន់ទៅកាន់ការសម្រេចគោលបំណងនោះ។»

ដៃគូរបស់កម្មវិធីរក្សាសុវត្ថិភាពតាមផ្លូវ ក្រៅពី TWIS រួមមាន Bicycle Coalition, BuildON, EducationWorks ការិយាល័យផ្នែកទំនាក់ទំនងជាមួយពលរដ្ឋ និង អ្នកស្ម័គ្រចិត្ត របស់ចៅហ្វាយក្រុង ការិយាល័យផ្នែកអប់រំ របស់ចៅហ្វាយក្រុង ស្នងការដ្ឋានប៉ូលិសនៃក្រុងហ្វីឡាដែលហ្វ្យា៉ PhillyRising Collaborative ការិយាល័យផ្នែកសន្តិសុខរបស់សាធារណៈ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា៉ និង ប៉ូលិសរបស់ SEPTA។

មាតាបិតា និងសមាជិកសហគមន៍ ដែលចង់ចូលរួមជាមួយកម្មវិធី WalkSafePHL គប្បីទាក់ទង Anthony Murphy តាមរយៈអ៊ីមែល Anthony.murphy@phila.gov។



### តើយើងធ្វើបានដូចម្តេច?

ចំណុចសំខាន់ៗអំពីការរីកចម្រើនក្នុងការរៀបចំសាលាទទួលសិស្សរបស់ក្រសួង សម្រាប់ឆ្នាំសិក្សាថ្មី៖

| | |
|---|---|
| **ចំនួនភាគរយ នៃ...** | |
| សាលាទទួលសិស្ស ដែលបានទទួលការកែលម្អអាគាររួចរាល់ហើយ | ៦៨% |
| សាលាទទួលសិស្ស ដែលបានបញ្ជាក់ថាមាននាយកសាលានៅឆ្នាំក្រោយ | ៩៨% |
| **ចំនួននៃ...** | |
| សាលាទទួលសិស្ស ដែលបានបញ្ជាក់ថាមានកម្មវិធីក្រៅម៉ោងសិក្សា សម្រាប់ឆ្នាំក្រោយ | ២០% |

## *ការចុះឈ្មោះ និងការវាយតម្លៃ ពិសេស សម្រាប់សិស្សានុសិស្សអន្តោប្រវេសន៍ ដែលទើបមកដល់ថ្មី ចាប់ផ្តើមនៅខែសីហា*

ការិយាល័យផ្នែក កម្មវិធី និងកម្មវិធីសិក្សា ភាសាចម្រុះ នឹងជួយក្មេងដែលទើបមកដល់ប្រទេសនេះថ្មី បំពេញលិខិតចុះឈ្មោះចូលរៀន សម្រាប់សិស្សថ្មី ដោយមានជំនួយផ្នែក បកប្រែភាសា និងបកប្រែឯកសារ ក្នុងខែសីហា។

សេវាកម្មនេះនឹងមានពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ ខែសីហា នៅមណ្ឌលវាយតម្លៃសិស្សដែលនិយាយភាសាចម្រុះរបស់ក្រសួងអប់រំ (MAC) ដែលស្ថិតនៅអាស័យដ្ឋានលេខ 440 North Broad Street, ជាន់ទី១ បន្ទប់លេខ ១១៩៥។ នឹងមានបុគ្គលិកចាំជួយពន្យល់អំពីវិធី ចុះឈ្មោះ ពិនិត្យវាយតម្លៃចំណេះដឹងរបស់ក្មេងសម្រាប់ថ្នាក់ ESOL ហើយផ្តល់ជំនួយ និងព័ត៌មាន អំពីក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា។

ឆ្នាំមុន MAC បានចុះឈ្មោះ និងវាយតម្លៃ សិស្សានុសិស្សជាង៨០០នាក់ ដែលមកពីប្រទេសជាង ៧០ ដែលនិយាយភាសាជាង ៤០ ភាសា ខុសៗគ្នា។

សូមទាក់ទងមណ្ឌលវាយតម្លៃសិស្សដែលនិយាយភាសាចម្រុះលេខ ២១៥-៤០០-៤២៤០ រើសយកលេខ១ ដើម្បីព័ត៌មានបន្ថែម និង/ឬ ដើម្បីធ្វើការណាត់ជួប។

| | |
|---|---|
| **អំពី៖** | ជំនួយក្នុងការចុះឈ្មោះ សម្រាប់ក្រុមគ្រួសារដែលមានកូនទើបមកដល់ប្រទេសនេះក្នុងពេលថ្មីៗ |
| **ទីកន្លែង៖** | 440 North Broad Street, ជាន់ទី១ បន្ទប់លេខ ១១៩៥ |
| **កាលបរិច្ឆេទ៖** | ពីថ្ងៃទី៥ ដល់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣<br>ពីថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ ពីម៉ោង ៨:៣០ ព្រឹក ដល់ ៦ ល្ងាច |




## លេខដែលគេខ្វល់ខ្វាយញឹកញាប់ (លេខទូរស័ព្ទ)

| បើសិនជាលោកអ្នកមានសំណួរអំពី... | លេខទូរស័ព្ទ |
|---|---|
| **ការបង្កើន និងការគាំទ្រដល់ ការសិក្សា៖** ផ្តល់ការណែនាំ និងការហ្វឹកហ្វឺនផ្នែកការងារដល់គ្រូ ផ្នែក ដន្ត្រី សិល្បៈ របាំ ល្ខោន កាយវប្បកម្ម ក្រៅម៉ោងសិក្សា កីឡា បណ្ណាល័យ និង ភាសាបរទេស | ២១៥-៤០០-៥៩២០ |
| **វត្តមានអវត្តមាន និងការគេចសាលា៖** ផ្តល់ជំនួយដល់សាលា ដើម្បីកែលម្អវត្តមានអវត្តមាន និងកាត់បន្ថយការគេចសាលា របស់សិស្ស | ២១៥-៤០០-៤២២០ |
| **ការអប់រំអំពី អាជីព និងបច្ចេកវិទ្យា៖** ផ្តល់កម្មវិធី និងសេវា សម្រាប់សិស្សានុសិស្សចូលរួមក្នុងការអប់រំអំពី អាជីព និងបច្ចេកវិទ្យា | ២១៥-៤០០-២៣៣១ |
| **ថ្នាក់មុនមត្តេយ្យ៖** ផ្តល់កម្មវិធី និងជំនួយ សម្រាប់ក្មេង ចាប់ពីពេលកើត ដល់ អាយុប្រាំមួយឆ្នាំ និងក្រុមគ្រួសាររបស់ពួកគេ | ២១៥-៤០០-៤២៧០ |
| **ការចូលរួមរបស់ ក្រុមគ្រួសារ និងសហគមន៍៖** ធ្វើឲ្យក្រុមគ្រួសារ និងសហគមន៍ អាចទាក់ទង និងអាចចូលរួមក្នុង កម្មវិធី និងជំនួយ របស់ក្រសួង | ២១៥-៤០០-៤១៨០ |
| **ការអប់រំផ្នែកភាសាចម្រុះ៖** ផ្តល់ជំនួយ និងការគាំទ្រ ផ្នែកភាសាចម្រុះ ដល់សិស្សានុសិស្ស និងក្រុមគ្រួសារ | ២១៥-៤០០-៤២៤០ |
| **ការចាត់តាំងសិស្ស៖** វាយតម្លៃសំណើសុំផ្លាស់ប្តូរសាលារបស់សិស្ស ហើយសម្រេចការចាត់តាំងសិស្សទៅតាមសាលា | ២១៥-៤០០-៤២៩០ |
| **សំណុំឯកសាររបស់សិស្សានុសិស្ស៖** រក្សា និង រៀបចំសំណើសម្រាប់សំណុំឯកសាររបស់សិស្ស(ព្រឹត្តិបតពិន្ទុ ការបញ្ជាក់អះអាង ដីកា សំណុំឯកសារសិស្សពិការ ។ល។) | ២១៥-៤០០-៤៧៨០ |
| **ការបម្រើពិសេស៖** ផ្តល់ការអប់រំពិសេស ជំនួយពិសេស និងការបម្រើផ្នែកសុខភាពរបស់សិស្ស | ២១៥-៤០០-៤១៧០ |
| **សន្តិសុខរបស់សាលា៖** ចូលរួមជាមួយ រដ្ឋបាលសាលា ប៉ូលីស សិស្សានុសិស្ស មាតាបិតា និងសមាជិកសហគមន៍ ដើម្បីបង្កើនសុវត្ថិភាពរបស់សិស្ស នៅក្នុង និងនៅជុំវិញ សាលា | ២១៥-៤០០-៤៧១០ |
| **យានជំនិះ៖** ផ្តល់យានជំនិះដែលមានសុវត្ថិភាពដល់សិស្សានុសិស្ស នៅក្នុងទីក្រុងហ្វីឡាដែលហ្វ្យា ដែលទៅរៀននៅសាលារដ្ឋ សាលាឆាធ័រ សាលាសាសនា និងសាលាឯកជន | ២១៥-៤០០-៤៣៥០ |
| **ព័ត៌មានទូទៅ** | ២១៥-៤០០-៤០០០ |

### អង្គការ United Way ផ្តល់ប្រាក់ចំនួន ៥០.០០០$ សម្រាប់ជួយដល់ការផ្លាស់ប្តូរ

អង្គការ United Way of Greater Philadelphia និង Southern New Jersey (UWGPSNJ) បានផ្តល់ប្រាក់ចំនួន ៥០.០០០$ ដល់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា កាលពីសប្តាហ៍កន្លងទៅនេះ ដើម្បីជួយសម្រួលដល់សិស្សានុសិស្សមកពីសាលាដែលបិទ ផ្លាស់ប្តូរទៅថ្នាក់រៀនថ្មីរបស់ពួកគេឲ្យបានស្រួល នៅខែកញ្ញានេះ។

ប្រាក់ជំនួយនេះ គឺជាការរួមសហការរវាង អង្គការ UWGPSNJ និង Public Citizens for Children and Youth (PCCY) នឹងជួយដល់នាយកសាលានៅសាលាប្រហែល៤០ ក្នុងការរៀបចំកម្មវិធីដែលចំណាយប្រាក់បន្តិចបន្តួច ដើម្បីស្វាគមន៍ និងឲ្យសិស្សានុសិស្ស និងមាតាបិតា ចូលមកសាលាថ្មី។

PCCY Public Citizens for Children and Youth

### *ការចុះឈ្មោះសិស្សទូទៅចាប់ផ្តើមនៅ ថ្ងៃច័ន្ទ ទី១៩ ខែសីហា*

*ការចុះឈ្មោះនឹងបើកនៅសាលាក្នុងតំបន់ នៅថ្ងៃច័ន្ទ ទី១៩ ខែសីហា។*
*ម៉ោងសម្រាប់ការចុះឈ្មោះមានដូចតទៅ៖*

*ថ្ងៃច័ន្ទ អង្គារ ព្រហស្បតិ៍ និង សុក្រ៖ ពីម៉ោង ៨ ព្រឹក ដល់ ១ រសៀល*
*ថ្ងៃពុធ៖ ពីម៉ោង ១១ ព្រឹក ដល់ ៤ ល្ងាច*

*មាតាបិតាអាចប្រើ School Finder ដែលមាននៅក្នុងវ៉ិបសៃរបស់ក្រសួង ដើម្បីសម្រេចការជ្រើសរើស សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលមានសម្រាប់សិស្សានុសិស្សនៅក្នុងតំបន់ដែលពួកគេរស់នៅ៖* www.philasd.org/schoolfinder.

*មាតាបិតាក៏ត្រូវពិនិត្យមើលបញ្ជីឯកសារដែលត្រូវការសម្រាប់ការចុះឈ្មោះ ដែលមាននៅក្នុងវ៉ិបសៃនៃការបើកសាលា មុនពេលទៅកាន់សាលាដែលនៅក្នុងតំបន់របស់ពួកគេ ដើម្បីបំពេញការចុះឈ្មោះចូលរៀន៖* www.philasd.org/schoolopening.